# សាកលវិទ្យាល័យស្វាយរៀង

គម្រោង៖ **ERASMUS+ PROGRAMME, KEY ACTION 2, CAPACITY BUILDING IN HIGHER EDUCATION**

## ប្រធានបទ៖ **ការពង្រីកសមត្ថភាពទំនាក់ទំនងអន្តរជាតិ និងការផ្សារភ្ជាប់អន្តរវប្បធម៌ ដើម្បីភាពចម្រុះ និងគាំទ្រអន្តរជាតូបនីយកម្មនៅគ្រឹះស្ថាន**

**Furthering International Relations Capacities and Intercultural Engagement to Nurture Campus Diversity and to Support Internationalization at Home**

កម្មវិធី៖ **HOME AWAY FROM HOME PROGRAMME**

## ១. សេចក្តីផ្តើម

គម្រោង FRIENDS គឺជាគម្រោងមួយដែលបានទទួលការគាំទ្រមូលនិធិពីកម្មវិធី Erasmus+ សម្រាប់ជួយអភិវឌ្ឍសមត្ថភាពឧត្តមសិក្សា។ គម្រោងនេះបង្កើតឡើងក្រោមការសហការនិងកិច្ចខិតខំប្រឹងប្រែងដោយ គ្រឹះស្ថានឧត្តមសិក្សា(HEIs) ចំនួន១២ នៃប្រទេសជាដៃគូ(Partner Countries)នៅអាស៊ី និងគ្រឹះស្ថានឧត្តមសិក្សា (HEIs) ចំនួន ៤ នៃប្រទេសកម្មវិធី(Program countries)នៅសហភាពអឺរ៉ុប។ FRIENDS បង្កើតឡើងក្នុងគោលគំនិតនៃ អន្តរជាតូបនីយកម្មនៅក្នុងគ្រឹះស្ថាន និង ការកសាងសមត្ថភាពសម្រាប់ការងារនេះ ក្នុងប្រទេសជាដៃគូទាំងប្រាំដែលចូលរួមក្នុងគម្រោងរួមមាន ប្រទេសប៊ូតាន់ កម្ពុជា ម៉ាឡេស៊ី ហ្វីលីពីន និងប្រទេសថៃ។ កម្មវិធី The Home Away from Home Programme ត្រូវបានបង្កើតឡើងដើម្បីបំពេញនូវតម្រូវការរបស់និស្សិតអន្តរជាតិ និងនិស្សិតដែលមានវប្បធម៌ចម្រុះ កំពុងសិក្សានៅគ្រឹះស្ថានទាំង១២នៃប្រទេសជាដៃគូ។ កម្មវិធីនេះគឺជាគម្រូមួយសម្រាប់ការគាំពារនិងការគាំទ្រដល់និស្សិត ដើម្បីបង្កើតនូវបរិយាកាសសិក្សាមួយ ដែលមានភាពកក់ក្តៅ ស្និទ្ធស្នាល និង លើកទឹកចិត្តសម្រាប់និស្សិតអន្តរជាតិ ដូចដែលបានលម្អិតនៅក្នុងឯកសារនេះ។

*This project has been funded with support from the European Commission. This publication reflects the views only of the author, and the Commission cannot be held responsible for any use which may be made of the information contained therein.*

ឯកសារនេះត្រូវបានរៀបចំបង្កើតឡើងផ្អែកតាមកិច្ចប្រជុំពិភាក្សា ការបំផុសគំនិត រៀបចំក្នុងកម្មវិធី The Home Away From Home Virtual Tea Party ដែលបានប្រារព្ធឡើងកាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០២០ ដោយមានការចូលរួមពីបុគ្គលិក៤៩រូប និងសមាជិកប្រតិបត្តិមកពីសហគមន៍FRIENDS។
មគ្គុទ្ទេសក៍នេះត្រូវបានកែសម្រួលឲ្យស្របនឹងស្ថានភាពជាក់ស្តែង និងត្រូវបានអនុម័តដាក់ឲ្យប្រើប្រាស់នៅក្នុងសកលវិទ្យាល័យស្វាយរៀង។

## ២. គោលនយោបាយ និងបទបញ្ញត្តិ

គោលនយោបាយ និងបទបញ្ញត្តិនេះមានសារៈសំខាន់ដោយបានបង្ហាញអោយឃើញថាវាជាភាពទទួលខុសត្រូវរបស់គ្រឹះស្ថាននីមួយៗដើម្បីផ្តល់ជូននិស្សិតអន្តរជាតិនូវសុវត្ថិភាព សន្តិសុខ និងបរិយាកាសមួយដែលមានការយកចិត្តទុកដាក់ ជួយគាំទ្រ និងផ្តល់អោយនូវរាល់តម្រូវការរបស់និស្សិតអោយបានស្របតាមការខិតខំប្រឹងប្រែង របស់ពួកគេដើម្បីអោយសម្រេចបានលទ្ធផលល្អប្រសើរក្នុងកំឡុងពេលសិក្សា ។
សាកលវិទ្យាល័យស្វាយរៀង(SRU) ធានានូវបរិយាកាសមួយដែលមាន សុខ សុវត្ថិភាព និង ការគាំពារដល់ភាពចម្រុះនៃវប្បធម៌ ដើម្បីគាំទ្រដល់និស្សិតអន្តរជាតិ និងនិស្សិតងាយរងគ្រោះ គ្រប់រូបបានទទួលទាំងចំណេះដឹង និងបទពិសោធអន្តរវប្បធម៌។

### ២.១. បុគ្គលិកគាំទ្រ

សាកលវិទ្យាល័យស្វាយរៀងមានបុគ្គលិក ២ (ពីរ) រូប សម្រាប់ជួយគាំទ្រនិស្សិត ស្របតាមគោលនយោបាយអោយបានល្អប្រសើ។ បុគ្គលិកទាំង២រូបនេះបំពេញការងារទៅតាមម៉ោងពេលការងាររបស់គ្រឹះស្ថាន និង ទៅតាមភាពចាំបាច់ជាក់ស្តែង ចូលរួមដោះស្រាយទៅលើសុខុមាលភាព និងសុវត្ថិភាពសម្រាប់និស្សិតទាំងអស់ដោយផ្ទាល់ តាមទូរស័ព្ទ ប្រព័ន្ធផ្សព្វផ្សាយសង្គម ឬតាមមធ្យោបាយទំនាក់ទំនងផ្សេងៗទៀត។

### ២.២. ទំនាក់ទំនងបន្ទាន់ ២៤/៧

សាកលវិទ្យាល័យស្វាយរៀងមានបុគ្គលិក២(ពីរ)រូបទទួលខុសត្រូវចំពោះករណីមានកិច្ចការបន្ទាន់ទាក់ទងនឹងនិស្សិតបរទេស ដែលនឹងចូលទៅក្នុងការដោះស្រាយក្នុងរយៈពេល២០នាទីយ៉ាងយូរ។ បុគ្គលិកទាំងពីរ ជ្រើសចេញពីការិយាល័យទំនាក់ទំនងអន្តរជាតិ និងមកពីមហាវិទ្យាល័យភាសាបរទេស។

### ២.៣. ឯកសារសិក្សា

*This project has been funded with support from the European Commission. This publication reflects the views only of the author, and the Commission cannot be held responsible for any use which may be made of the information contained therein.*

សាកលវិទ្យាល័យស្វាយរៀងផ្តល់ការគាំទ្រ ដើម្បីធានាថា ឯកសារចាំបាច់នានាបានដល់ដៃនិស្សិតនិង យល់ជ្រួតជ្រាបដើម្បីបង្កលក្ខណៈសិក្សាដល់ពួកគេនៅសាកលវិទ្យាល័យស្វាយរៀងបាន។

## ២.៤. សិទ្ធិ និងកាតព្វកិច្ចរបស់និស្សិតអន្តរជាតិ

រាល់ការអនុវត្តសិទ្ធិ និងកាតព្វកិច្ចទាំងអស់របស់និស្សិតទូទៅក៏ត្រូវបានអនុវត្តជាមួយនឹងនិស្សិតអន្តរជាតិផងដែរ។ និស្សិតអន្តរជាតិត្រូវអនុវត្ត និងគោរពតាមរាល់បទបញ្ញត្តិរបស់សាលា (ដូចជា ការលួចចម្លងពេលប្រលង ការលួចចម្លងឯកសារផ្សេងៗ ឬកម្មសិទ្ធិបញ្ញាជាដើម...)។ និស្សិតអន្តរជាតិនឹងបានទទួលព័ត៌មានជាក់លាក់និងយល់ច្បាស់អំពីបទបញ្ញត្តិដែលបានកំណត់ដោយគ្រឹះស្ថាន។

# ៣. ការគាំពារនិងគាំទ្រដល់និស្សិត

## ៣.១. ការគាំទ្រការសិក្សា

### ការណែនាំមុនពេលមកដល់

សាកលវិទ្យាល័យស្វាយរៀងនឹងផ្តល់ជូនតាមអនឡាញជាភាសាអង់គ្លេស នូវកូនសៀវភៅមគ្គុទ្ទេសក៍ សៀវភៅព័ត៌មានសម្រាប់និស្សិត គេហទំព័រឬអង្គភាពពាក់ព័ន្ធ រួមបញ្ចូលទាំងព័ត៌មានសំខាន់ៗដែលទាក់ទងនឹងការរៀបចំខ្លួនសម្រាប់ការសិក្សានៅសាកលវិទ្យាល័យស្វាយរៀង យល់ដឹងជាមុននូវអ្វីដែលអាចជួបប្រទះ ព្រមទាំងតម្រូវការ និងការគាំទ្រផ្នែកការសិក្សា។ និស្សិតនឹងទទួលបានការធានា តាមរយៈការប្រឹក្សាតាមប្រព័ន្ធអេឡិកត្រូនិក ឬការប្រឹក្សាដោយផ្ទាល់មុនពេលមកដល់ ដើម្បីជូនដំណឹងដល់ពួកគេពីកម្មវិធីសិក្សា ឯកទេសតាមផ្នែកនីមួយៗ និងព័ត៌មានសំខាន់ៗដែលត្រូវត្រៀមទុកជាមុន។

### កម្មវិធីតម្រង់ទិស

សាកលវិទ្យាល័យនឹងរៀបចំកម្មវិធីតម្រង់ទិស (ដូចជាសប្តាហ៍តម្រង់ទិស) ដើម្បីណែនាំនិស្សិតអំពីសេវាសិក្សា (ឧ: បណ្ណាល័យ ព័ត៌មានវិទ្យា ផ្នែកសេវាកម្មនិស្សិត និងការិយាល័យសិក្សា) ព្រមទាំងសកម្មភាពសង្គម និងសកម្មភាពកំសាន្តនានា ដើម្បីសម្រួលដល់ការផ្តល់ដំបូន្មានពីរការសិក្សាដំបូង ជូនដំណឹងដល់និស្សិតបរទេសពីច្បាប់ និងបទបញ្ជាផ្ទៃក្នុងរបស់គ្រឹះស្ថាន បញ្ជាក់ពីតម្រូវការសំខាន់ៗនៃកម្រិតនីមួយៗ និងផែនការនៃការសិក្សា។ ការតម្រង់ទិសនឹងរួមបញ្ចូលទាំងទស្សនកិច្ចក្នុងបរិវេណសាលា ភាពងាយស្រួលផ្សេងៗ និងដំណើរកំសាន្តក្នុងតំបន់ ។ល។ គ្រឹះស្ថានឧត្តមសិក្សានឹងណែនាំនិស្សិតថ្មីឱ្យមកដល់ ពីរ បី ថ្ងៃមុនពេលកំណត់ដើម្បីចូលរួមក្នុងកម្មវិធីតម្រង់ទិសមុនពេលដែលពួកគេចាប់ផ្តើមចូលរៀន។

*This project has been funded with support from the European Commission. This publication reflects the views only of the author, and the Commission cannot be held responsible for any use which may be made of the information contained therein.*

### អ្នកណែនាំ ឬអ្នកប្រឹក្សាអំពីការសិក្សា

សាកលវិទ្យាល័យស្វាយរៀង (SRU) នឹងធានាថាមានអ្នកប្រឹក្សាអំពីការសិក្សា ឬសមាជិកបុគ្គលិកចាត់តាំងណាម្នាក់ដែលអាចជួយ និងណែនាំដល់និស្សិត អំពីបញ្ហាប្រចាំថ្ងៃដែលទាក់ទងនឹងការសិក្សារបស់ពួកគេ ។ អ្នកណែនាំ ឬអ្នកប្រឹក្សាត្រូវត្រួត ពិនិត្យការសិក្សារបស់និស្សិត មធ្យមភាគពិន្ទុសរុប (GPA) និងចំនួនវត្តមាន ព្រមទាំងធានាថានិស្សិតទទួលបានការពេញចិត្តជាមួយវគ្គសិក្សានេះ និងដើម្បីផ្តល់នូវការជួយគាំទ្រឱ្យទាន់ពេលវេលាប្រសិនបើចាំបាច់ ។

### ការគាំទ្រផ្នែកភាសា

និស្សិតភាគច្រើនមិនមែនជាជនជាតិដើម ដែលនិយាយភាសាអង់គ្លេស ឬភាសាខ្មែរទេហើយទោះបីជាពួកគេបង្ហាញពីសមត្ថភាពភាសាអង់គ្លេស សម្រាប់គោលដៅនៃការសិក្សាក៏ដោយ ក៏ប៉ុន្តែពួកគេភាគច្រើននៅតែមានបញ្ហាក្នុងការនិយាយភាសាអង់គ្លេស និងមានផលពិបាកជាច្រើនក្នុងការប្រឡងបញ្ចប់ ដែលវាជាតម្រូវការរបស់គ្រឹះស្ថានឧត្តមសិក្សាជាច្រើន។ វាជះឥទ្ធិពលយ៉ាងខ្លាំងដល់ទាំងការសិក្សា និងការកែសម្រួលផ្នែកសង្គមរបស់ពួកគេ។ សាកលវិទ្យាល័យនឹងផ្តល់ការគាំទ្រផ្នែកការសិក្សាភាសាអង់គ្លេស ទាំងក្នុងទម្រង់ការស្វ័យសិក្សាតាមប្រព័ន្ធអ៊ីនធឺណិត (Internet) ឬវគ្គសិក្សាឯកទេសភាសាអង់គ្លេស ឬការបង្រៀនផ្ទាល់ រួមទាំងថ្នាក់បង្រៀនត្រៀមប្រឡងផ្សេងៗ។ និស្សិតក្នុងប្រទេសនីមួយៗ ដែលពូកែភាសាអង់គ្លេស ឬក្លឹបសិក្សារបស់និស្សិតអាចជួយនិស្សិតឱ្យបង្កើនជំនាញភាសាអង់គ្លេសរបស់គេ ឬជំនួយដល់មុខវិជ្ជាដទៃទៀតដែលពួកគេជួបប្រទះនឹងការលំបាក ។ បន្ថែមពីនេះទៅទៀត សាកលវិទ្យាល័យនឹងរៀបចំថ្នាក់សិក្សាភាសាជាតិកម្រិតមូលដ្ឋានដល់និស្សិតបរទេស ដើម្បីឱ្យនិស្សិតបរទេស អាចប្រើប្រាស់បានទាំងក្រៅថ្នាក់រៀន ឬក្រៅបរិវេណសាកលវិទ្យាល័យ ។

## ៣.២. សមាហរណកម្មវប្បធម៌ និងសង្គម

### ប្រព័ន្ធដៃគូសហការ

សាកលវិទ្យាល័យស្វាយរៀង (SRU) នឹងចាត់តាំងតំណាងនិស្សិត និងកម្មវិធីសហការដើម្បីជាជំនួយដល់និស្សិតដទៃទៀត ។ និស្សិតទាំងនេះ នឹងធ្វើបដិសណ្ឋារកិច្ច រៀបចំទស្សនកិច្ចក្នុងបរិវេណសាកលវិទ្យាល័យ និងចាត់ចែងដំណើរកំសាន្តនៅក្នុងមូលដ្ឋានដល់និស្សិត ព្រមទាំងជួយសម្រួលបញ្ហាបច្ចេកទេស ដូចជាការបើកគណនីធនាគារជាដើម ។

*This project has been funded with support from the European Commission. This publication reflects the views only of the author, and the Commission cannot be held responsible for any use which may be made of the information contained therein.*

និស្សិតបរទេស អាចជួបមិត្តភក្តិថ្មីៗរបស់ពួកគេ ក្នុងកំឡុងពេលធ្វើការតម្រង់ទិស ឬអាចជួបមុនពេលមកដល់គ្រឹះស្ថាន តាមរយៈទំនាក់ទំនងតាមប្រព័ន្ធអ៊ីនធឺណែត។ មិត្តនិស្សិត នឹងបង្ហាញពីបរិយាកាសក្នុងប្រទេសរបស់ខ្លួន ជុំវិញវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី របៀបធ្វើម្ហូបអាហារ ដល់និស្សិតថ្មីៗ ។

**កម្មវិធីស្វាគមន៍ និងតម្រង់ទិស**

នៅក្នុងកម្មវិធីតម្រង់ទិស នឹងមានការធ្វើបទបង្ហាញពីវប្បធម៌ក្នុងតំបន់ ហើយនិស្សិតនឹងត្រូវបានណែនាំពីទិដ្ឋភាពសង្គមក្នុងអង្គភាព ក្រៅពីផ្នែកការសិក្សា ។ ការតម្រង់ទិស ក៏បានណែនាំនិស្សិត អំពីវិធាន និងគោលនយោបាយ ដែលអាចជួយធានាសុវត្ថិភាពដល់ពួកគេបានក្នុងការស្នាក់នៅ ។ មានព្រឹត្តិការណ៍ផ្សេងៗជាច្រើនដែលនឹងត្រូវបានប្រារព្ធឡើងដើម្បីតម្រង់ទិស និងស្វាគមន៍ដល់និស្សិតថ្មីៗ ។ ពិធីអាហារជួបជុំសម្រាប់និស្សិតឆ្នាំទីមួយ ឬព្រឹត្តិការណ៍សង្គមផ្សេងៗទៀត នឹងត្រូវបានប្រារព្ធឡើង ដើម្បីឱ្យនិស្សិតបរទេសបានជួបជាមួយនឹងរៀមច្បង និងស្គាល់គ្នាជាមួយមិត្តរួមថ្នាក់ថ្មីៗរបស់ពួកគេ ។

**ទំនាក់ទំនងជាមួយបុគ្គលិកក្នុងអង្គភាព**

សាកលវិទ្យាល័យស្វាយរៀង (SRU) នឹងភ្ជាប់ទំនាក់ទំនងនិស្សិតជាមួយនឹងបុគ្គលិក និងការិយាល័យដែលពាក់ព័ន្ធនានា ដូចជាផ្នែកទំនាក់ទំនងអន្តរជាតិ ផ្នែកបែងចែកការងារនិស្សិត ឬផ្នែកផ្សេងទៀតដែលទាក់ទងនឹងការស្នាក់នៅរបស់ពួកគេនៅក្នុងគ្រឹះស្ថាន ។ ក្នុងន័យនេះ និស្សិតអាចស្គាល់មនុស្សដែលពួកគេអាចទាក់ទងបាន នៅពេលដែលមានការលំបាកក្នុងទំនាក់ទំនងសមាហរណកម្មសង្គម កំឡុងពេលការសិក្សារបស់ពួកគេ ។ និស្សិតបរទេសក៏អាចទទួលបានឱកាសធ្វើការជានិស្សិតហាត់ការ នៅក្នុងការិយាល័យណាមួយរបស់គ្រឹះស្ថាន ដូចជាការិយាល័យទំនាក់ទំនងអន្តរជាតិ បណ្ណាល័យ ឬនៅការិយាល័យសិក្សា ។

**សកម្មភាពវប្បធម៌**

សាកលវិទ្យាល័យស្វាយរៀង (SRU) រៀបចំសកម្មភាព និងព្រឹត្តិការណ៍វប្បធម៌នានាជាទៀងទាត់ សម្រាប់និស្សិតចូលរួមជាមួយគ្នា ដើម្បីចែករំលែកនូវវប្បធម៌ផ្ទាល់ខ្លួនរបស់ពួកគេ។ សកម្មភាពផ្លាស់ប្តូរវប្បធម៌គ្នា អាចនឹងធ្វើឡើងចំថ្ងៃសម្រាក ឬថ្ងៃបុណ្យអន្តរជាតិ ដែលរួមបញ្ចូលការចម្អិនអាហារ ការច្រៀង និងការរាំកំសាន្តនានា។ ព្រឹត្តិការណ៍ពហុវប្បធម៌នេះ ក៏ លើកទឹកចិត្តឱ្យមានវប្បធម៌ចម្រុះគ្នា នៅក្នុងបរិវេណសាកលវិទ្យាល័យ និងផ្តល់នូវឱកាសជូននិស្សិតបរទេស ដើម្បីចែករំលែកអំពីទំនៀមទម្លាប់ ប្រពៃណីផ្ទាល់ខ្លួនរបស់ពួកគេផងដែរ។ សាកលវិទ្យាល័យស្វាយរៀង (SRU) ក៏មានការចូលរួមពីនិស្សិតផងដែរ នៅក្នុងពិធីបុណ្យប្រពៃណីជាតិ និងពិធី

*This project has been funded with support from the European Commission. This publication reflects the views only of the author, and the Commission cannot be held responsible for any use which may be made of the information contained therein.*

បុណ្យសាសនាដទៃទៀត ។ សកម្មភាពវប្បធម៌មួយចំនួន ត្រូវបានរៀបចំឡើងដោយសាកលវិទ្យាល័យស្វាយរៀង (SRU) ដើម្បីអបអរសាទរដល់វប្បធម៌ចម្រុះគ្នា នៅក្នុងបរិវេណសាកលវិទ្យាល័យ អាចជា: Erasmus Day, International Day, Multicultural Night, បុណ្យឯករាជ្យជាតិ (នៃប្រទេសនីមួយៗ) បុណ្យចូលឆ្នាំចិន International Students Evening, International Food Festival ថ្ងៃបុណ្យនៃសេចក្តីស្រលាញ់ បុណ្យចូលឆ្នាំខ្មែរ បុណ្យភ្ជុំបិណ្ឌ ។ល។ លើសពីនេះទៅទៀត វប្បធម៌ចម្រុះគ្នាក្នុងនៅបរិវេណសាកលវិទ្យាល័យ អាចត្រូវបានបង្ហាញផងដែរ ក្នុងកំឡុងថ្ងៃទិវាកីឡាអន្តរជាតិ ឬការប្រកួតប្រជែងនានា ដោយធ្វើការប្រមូលផ្តុំនិស្សិត ដើម្បីប្រកួតគ្នាទៅតាមកីឡាប្រពៃណី និងកីឡាធម្មតាទូទៅ ។ សកម្មភាពទាំងនេះ អាចត្រូវបានប្រព្រឹត្តទៅដោយមានកិច្ចសហប្រតិបត្តិការរវាងក្លឹបសិក្សានិស្សិតផ្សេងៗនៅក្នុងគ្រឹះស្ថាន និងអាចមានល្បែងប្រជាប្រិយប្រពៃណី ដែលមានភាពរស់រវើកផងដែរ។

## ៣.៣. ជីវិតនៅសាកលវិទ្យាល័យ រួមបញ្ចូលទាំងអគារ បរិក្ខារ និងការស្នាក់នៅ

សាកលវិទ្យាល័យស្វាយរៀង (SRU) នឹងចាត់ចែងផ្គត់ផ្គង់រាល់ការស្នាក់នៅដល់និស្សិតបរទេស ដើម្បីទទួលបាននូវបទពិសោធន៍រស់នៅយ៉ាងល្អប្រសើរ តាមរយៈការផ្តល់ជូននូវអគារ និងបរិក្ខារដែលមានគុណភាព ព្រមទាំងកន្លែងស្នាក់នៅប្រកបដោយផាសុកភាព ដើម្បីជួយពួកគេឱ្យទទួលបាននូវបទពិសោធន៍ល្អបំផុត ក្នុងជីវិតនៅសាកលវិទ្យាល័យ ។ សេវាថែទាំ និងការគ្រប់គ្រងក្នុងបរិវេណសាកលវិទ្យាល័យដែលអាចទុកចិត្តបាន ក៏មានភាពច្បាស់លាស់ដែលអាចទទួលយកបានផងដែរ។ សេវាផ្សេងៗមានស្រាប់ និងសេវាដែលអាចផ្តល់ជូនតាមតម្រូវការជាក់ស្តែងមានដូចជា៖

- FRIENDS Teahouse
- បន្ទប់អធិដ្ឋាន សម្រាប់អ្នកកាន់សាសនាមូស្លីម/ បន្ទប់សម្រាប់ពហុជំនឿ
- បណ្ណាល័យផ្តល់ជូនសៀវភៅតាមអ៊ិនធឺណែត និងទស្សនាវដ្តីសិក្សាស្រាវជ្រាវ
- ទីតាំងដែលប្រើប្រាស់ភាសាអង់គ្លេស/ទីតាំងដែលនិយាយភាសារបរទេសផ្សេងទៀត
- ក្លឹបសិក្សារបស់និស្សិត និងសង្គម
- ផ្តល់ Wi-Fi ដោយឥតគិតថ្លៃនៅក្នុងបរិវេណសាកលវិទ្យាល័យ
- ហាងកាហ្វេ តូបលក់សៀវភៅ និងអាហារដ្ឋាន ក្នុងបរិវេណសាកលវិទ្យាល័យ

ក្រៅពីការគាំទ្រនៅក្នុងបរិវេណសាកលវិទ្យាល័យ ពួកគេក៏ត្រូវបានផ្តល់ជូនបន្ថែមពី ការិយា ល័យទំនាក់ទំនងអន្តរជាតិ ការិយាល័យកិច្ចការនិស្សិត និងមហាវិទ្យាល័យភាសាបរទេស។

*This project has been funded with support from the European Commission. This publication reflects the views only of the author, and the Commission cannot be held responsible for any use which may be made of the information contained therein.*

## ៣.៤. ជំនួយការក្នុងបរិវេណសាកលវិទ្យាល័យ

សាកលវិទ្យាល័យស្វាយរៀង (SRU) បានចាត់តាំងបុគ្គលិក១រូប ដើម្បីទំនុកបម្រុងនិស្សិតបរទេស ក្នុងរយៈពេលនៃការសិក្សារបស់ពួកគេ ។ ដូច្នេះ សមាជិកបុគ្គលិកត្រូវបានចាត់ឱ្យផ្តល់ការណែនាំ និងជំនួយដល់និស្សិតបរទេស ក្នុងកិច្ចការធ្វើទិដ្ឋាការ និង អន្តោប្រវេសន៍ផ្សេងទៀត ។ ក្នុងអំឡុងពេលតម្រង់ទិស មន្ត្រីអន្តោប្រវេសន៍អាចត្រូវបានអញ្ជើញ ដើម្បីថ្លែងអំពីនីតិវិធីអន្តោប្រវេសន៍ និងឆ្លើយសំណួរនានា ជូននិស្សិតបរទេស ។ គ្រឹះស្ថាននឹងរៀបចំឲ្យមានកម្មវិធីជួបជុំ រវាងមន្ត្រី/អ្នកជំនាញអន្តោប្រវេសន៍ ជាមួយបុគ្គលិក និងនិស្សិតអន្តរជាតិ ដើម្បីផ្តល់សេវាកម្មដល់ក្នុងបរិវេណសាកលវិទ្យាល័យ។

## ព័ត៌មានគាំទ្រ

សាកលវិទ្យាល័យស្វាយរៀង (SRU) នឹងបញ្ជូនព័ត៌មានទៅកាន់សហគមន៍អន្តរជាតិតាមរយៈគេហទំព័រជាភាសាអង់គ្លេសរបស់អង្គភាពខ្លួន ។ លើសពីនេះទៀត មហាវិទ្យាល័យនីមួយៗ អាចផ្តល់នូវព័ត៌មានជាភាសាអង់គ្លេសលើគេហទំព័ររបស់ខ្លួន ដែលមានព័ត៌មានសិក្សាចាំបាច់នានា សម្រាប់និស្សិតបរទេស ។ ហ្វេសប៊ុក និងតេឡេក្រាមក៏នឹងត្រូវបានប្រើប្រាស់ផងដែរ ហើយការប្រើប្រាស់ទាំងអស់ នឹងត្រូវបានផ្តល់ជាភាសាអង់គ្លេស។ បុគ្គលិកគាំទ្រ ដែលត្រូវបានចាត់តាំង និងនិស្សិតដែលអាចនិយាយភាសាអង់គ្លេសបាន នឹងបន្តផ្តល់ណែនាំនានាដល់និស្សិតបរទេស អំពីការផ្លាស់ប្តូរណាមួយដែលអាចជះឥទ្ធិពលដល់ពួកគេ តាមរយៈការកែប្រែគោលនយោបាយ របស់រាជរដ្ឋាភិបាលទាំងនៅថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ ។ ការកែប្រែនេះ ត្រូវបានធ្វើឡើងដោយក្រុមប្រឹក្សាសាកលវិទ្យាល័យស្វាយរៀង (SRU) ឬការប្រែប្រួលដទៃទៀត អាចនឹងប៉ះពាល់ដល់ពួកគាត់ ។

បានអនុម័តដោយគណៈគ្រប់គ្រងនៃសាកលវិទ្យាល័យនិងដាក់ឲ្យប្រើប្រាស់ចាប់ពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០២១

*This project has been funded with support from the European Commission. This publication reflects the views only of the author, and the Commission cannot be held responsible for any use which may be made of the information contained therein.*